# ចម្លាក់ព្រះយមនៅសម័យដំបូង

## (ករណីសិក្សា ចម្លាក់ព្រះយមនៅលើផ្ដែរទ្វារប្រាសាទភ្នំព្រះបាទ ខេត្តកំពង់ចាម)

ព្រះយម គឺជាអាទិទេពដ៏សំខាន់មួយក្នុងព្រហ្មញ្ញសាសនា ដែលគេស្គាល់ច្បាស់ថាជាទេពដែលស្គាល់សេចក្ដីស្លាប់ដំបូងគេ។ នៅសម័យដំបូង (សម័យមុនអង្គរ) យើងតែងតែឃើញបណ្ដាសាជាច្រើននៅក្នុងសិលាចារឹក ដែលគេដាក់បណ្ដាសាដល់ជនណាដែលហ៊ានបំផ្លាញ ឬលួចទ្រព្យសម្បត្តិនៅទេវស្ថាននឹងត្រូវធ្លាក់នរក។ ឧទាហរណ៍ សិលាចារឹកទួលអង្គដើងរាស់ ខេត្តកំពង់ស្ពឺ (ស.វ.ទី៧) រៀបរាប់ថា៖ "*គេតសកិគិនេះគ្វាងវ្រះគេទៅនរក្កយាវតសូយ៌្យស្យ្យចន្រ្ទស្យ្យតាវត៍នរកទុះខិតះ*" ដែលប្រែសម្រួលថា៖ "*អ្នកដែលលួចយកទ្រព្យសម្បត្តិក្នុងឃ្លាំងព្រះនឹងធ្លាក់ទៅរងទុកវេទនានៅស្ថាននរក ដរាបណាឱ្យតែព្រះអាទិត្យព្រះចន្ទ្រនៅមាន*"។[១] ឧទាហរណ៍នេះ ស្ដែងឱ្យឃើញថា មនុស្សខ្មែរបុរាណគោរពព្រហ្មញ្ញសាសនារឹងមាំណាស់ ហើយក៏ជឿលើបុណ្យបាប (សួគ៌ និងនរក) ឬគោរពប្រណិប័តន៍ព្រះយមដូចគ្នាដែរ។ ទោះបីជាយ៉ាងណា នៅសម័យដំបូងដដែលនេះ គេសង្កេតឃើញថា ចម្លាក់ព្រះយមមានតិចតួចបំផុត បើធៀបជាមួយចម្លាក់អាទិទេពដទៃទៀតនៅក្នុងព្រហ្មញ្ញសាសនា សូម្បីចម្លាក់ផ្ដាយនព្វគ្រោះ(ទេព៩)មួយផ្ទាំងដែលឆ្លាក់នៅស.វ.ទី៧ ក៏យើងពិបាកកំណត់ថាមួយណាជាព្រះយមបានឡើយ (រូបលេខ១)។ ប៉ុន្តែនៅសម័យអង្គរវិញ ចម្លាក់ព្រះយមគេឃើញមានច្រើនរាប់មិនអស់ដូចគ្នា ឧទាហរណ៍ ចម្លាក់ព្រះយមនៅប្រាសាទមេបុណ្យខាងកើត (រូបលេខ២) ចម្លាក់នៅប្រាសាទបន្ទាយស្រី (រូបលេខ៣) ចម្លាក់នៅ ចម្លាក់នៅប្រាសាទអង្គរវត្ត (រូបលេខ៤-៥) បដិមាព្រះយមជិះលើក្របីធ្វើពីលោហៈធាតុ (រូបលេខ៦)។ល។ នៅក្នុងអត្ថបទខ្លីនេះ យើងនឹងសិក្សាចម្លាក់ព្រះយមនៅសម័យដំបូង (ស.វ.ទី៧) ដ៏កម្រមួយដែលឆ្លាក់លើផ្ដែរប្រាសាទភ្នំព្រះបាទ ស្រុកជើងព្រៃ ខេត្តកំពង់ចាម។

នៅក្នុងទេវកថារឿងមហាភារត នៃព្រហ្មញ្ញសាសនា ព្រះយម គឺជាបិតារបស់យុធិស្ថិរ ហើយគម្ពីរជាច្រើនទៀតគេស្គាល់ថា ទ្រង់ គឺជាបុត្ររបស់ព្រះសូរ្យ (ព្រះអាទិត្យ) និងនាងសរន្យុ (សន្ធូន ឬសម្ជូន ដែលត្រូវជាបុត្រីរបស់ព្រះវិស្វកម៌) ហើយព្រះយម ក៏ជាបងប្រុសរបស់ស្រាទ្ធទេវមនុ និងជាប្អូនប្រុសរបស់ព្រះនាងយមិ (យមុនា) ដែរ។[២] គេជឿថា ព្រះយម គឺជាទេពដែលស្គាល់សេចក្ដីស្លាប់មុនគេ ហើយក៏ជាអ្នកដែលចាប់កំណើតមុនគេបង្អស់ដែរ ម៉្លោះហើយទើបគេចាត់ទុកទ្រង់ថា

[១] កំ វណ្ណារ៉ា ២០២០។

[២] Wilson 1895.

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

ជាទេពនៃអ្នកស្លាប់ ឬជាស្តេចនៃស្ថាននរក។[៣] សេនាកត់ត្រារបស់ព្រះយមមានពីរនាក់ គឺ ចិត្រគុប្ត (Citragupta) ជាអ្នកអានឈ្មោះអ្នកស្លាប់ និងម្នាក់ទៀតឈ្មោះ អគ្រសន្ធនី (Agra-Sandhani) ជាអ្នករៀបរាប់អំពីជីវិតរបស់បុគ្គលម្នាក់ៗ។[៤] ក្រៅពីនេះគេដឹងថា ព្រះយមមានឆ្កែពីរក្បាលដែលមានភ្នែកបួនជាសេនាផ្ទាល់របស់ទ្រង់ ដែលមានឈ្មោះថា ស្យាម (Śyama) និងមួយក្បាលឈ្មោះ សបល (Sabala)។ បន្ទាប់ពីអានពីទង្វើរបស់អ្នកស្លាប់កាលនៅរស់រួចមក ព្រះយមមានតួនាទីថ្លឹងថ្លែងអំពើល្អនិងអាក្រក់ដែលបុគ្គលបានកសាង រួចត្រូវសម្រេចថាឱ្យវិញ្ញាណរបស់អ្នកស្លាប់នោះអាចទៅស្ថានសួគ៌ (អ្នកប្រព្រឹត្តអំពើបុណ្យ) និងទៅរងទុក្ខវេទនានៅស្ថាននរក (អ្នកប្រព្រឹត្តអំពើបាប)។[៥] ត្រង់ន័យនេះ មានន័យថា រាល់មនុស្សដែលបានស្លាប់ហើយ ព្រលឹងបុគ្គលគ្រប់រូបត្រូវចាំបាច់ទៅជួបព្រះយមជាមុនសិន។ ព្រះយម គឺជាលោកបាលប្រចាំនៅទិសខាងត្បូង មានយានជំនិះជាសត្វក្របី និងមានព្រះហស្តកាន់ដំបង និងខ្សែចំណងដែលជាអាវុធទុកសង្គ្រោះជនរងគ្រោះ។[៦]

ដោយឡែក ចម្លាក់ផ្តែរទ្វារមកពីប្រាសាទភ្នំព្រះបាទដែលយកមកសិក្សានេះ គឺយើងឃើញខាងចុងសងខាងលម្អដោយរូបសត្វមករបែរចូលក្នុងខ្នាក់ក្បាច់បន្ទាត់ធ្នូ និងខាងក្រោមមានរំយោលផ្កាឬកម្រងមាលា ដែលជាលក្ខណៈទូទៅរបស់រចនាបថសំបូរព្រៃគុក[៧] (ស.វ.ទី៧) (រូបលេខ៧-៨)។ នៅចំពាក់កណ្តាលផ្តែរ យើងឃើញមានចម្លាក់ចំនួនបី គឺរូបកណ្តាលជាចម្លាក់ព្រះយម ឬយមរាជក្នុងកាយវិការពែនភ្នែនជិះលើសត្វក្របីមានស្នែងវែង ព្រះហស្តម្ខាងដាក់ទម្លាក់ចុះមកក្រោមក្បែរក្បាលជង្គង់ ព្រះហស្តម្ខាងទៀតដាក់មកដើមទ្រូងប្រដាប់ដោយដំបងមួយដែលចុងដំបងស្ថិតនៅកៀកស្មា រីឯព្រះភក្ត្រក្នុងទម្រង់សមាធិ (បិទព្រះនេត្រ) ព្រះកេសរួញស្រដៀងគូទខ្យងបួងឡើងទៅលើ ឬអាចមិនមែនកេសា តែបង្ហាញអំពីមួកម្យ៉ាងដែលមានជាយសងខាងធ្លាក់មកក្រោមស្រដៀងក្រវិលវែងៗ (រូបលេខ៩)។ ចំណែក រូបទេពនៅសងខាងវិញ គឺឈរនៅលើទម្រមួយរាងមូល ទំនងស្លៀកសំពត់ខ្លី (?) ព្រះហស្តទាំងពីរលើកមកហួសផ្ចិតបន្តិចប្រដាប់ដោយវត្ថុរាងមូលវែង ហើយការលម្អទម្រង់ព្រះភក្ត្រផ្នែកខាងលើស្រដៀងរូបទេពនៅកណ្តាលដែរ (រូបលេខ១០)។ ទេពទាំងពីរសងខាងនេះ អាចទំនងជាសេនាកត់ត្រារបស់ព្រះយមរាជ គឺម្នាក់ឈ្មោះ ចិត្រគុប្ត (Citragupta) ជាអ្នកអានឈ្មោះអ្នកស្លាប់ និងម្នាក់ទៀតឈ្មោះ អគ្រសន្ធនី (Agra-Sandhani) ជាអ្នករៀបរាប់អំពី

[៣] Macdonell 1995.

[៤] Roveda 2005.

[៥] Wilson 1895.

[៦] Roveda 2005.

[៧] Boisselier 1966.

ជីវិតរបស់បុគ្គលម្នាក់ៗ ព្រោះយើងមើលវត្ថុដែលកាន់ជាប់នឹងព្រះហស្តទាំងសងខាងនេះអាចជាឯកសារដែលគេរុំឱ្យមើលឬចងខ្សែ សម្រាប់អានពីឈ្មោះ និងប្រវត្តិបុគ្គលស្លាប់ម្នាក់ៗ។

ចម្លាក់បង្ហាញព្រះយម ឬយមរាជ ដោយមានសេនាកត់ត្រានៅសងខាង (?) របៀបនេះយើងមិនសូវប្រទះឃើញច្រើនឡើយនៅសម័យអង្គរ ពោល គឺច្រើនតែគេបង្ហាញព្រះយមជិះនៅលើសត្វក្របីរបៀបជារូបទោលតែឯង ឆ្លាក់នៅតាមផ្តែរទ្វារ ឬហោជាងនៅទិសខាងត្បូង។ ប៉ុន្តែទោះបីកម្រយ៉ាងណា ក៏យើងឃើញមានទម្រង់ស្រដៀងគ្នានេះមួយនៅលើផ្តែរទ្វារប្រាសាទវត្តភូ (សព្វថ្ងៃនៅស្រុកលាវ) (រូបលេខ១១) ដែលបង្ហាញព្រះយមកាន់ដំបងអង្គុយបញ្ឈរជង្គង់ម្ខាងនៅលើទម្រពាំងបួនជ្រុងមួយនៅចំកណ្តាលផ្តែរ និងតួអង្គពីរនាក់ទៀតមានពុកមាត់ និងពុកចង្កាវែងអង្គុយនៅលើទម្រពាំងបួនជ្រុង ដោយម្នាក់នៅខាងឆ្វេងអង្គុយបញ្ឈរជង្គង់ម្ខាងដៃកាន់វត្ថុអ្វីម្យ៉ាងបែរមុខមករកព្រះយមដែលទំនងជាព្រះចិត្រគុប្ត និងម្នាក់ទៀតអង្គុយចោងហោងដាក់ជង្គង់ទៅមុខស្មើដោយដៃទាំងពិរលើកប្រណម្យចំដើមទ្រូងដែលទំនងជាអគ្រ-សន្ធនី។[៨] អ្នកទាំងពីរនេះ សុទ្ធតែទ្រដោយដៃម្ខាងរបស់សត្វតោដូចគ្នា។ សព្វថ្ងៃ ព្រះចិត្រគុបត្ត ដែលជាសេនាកត់ត្រារបស់ព្រះយម គេនៅតែគោរពប្រតិបត្តិមកដល់សព្វថ្ងៃ ដែលយើងឃើញមានច្រើននៅស្រុកសៀម (រូបលេខ១២) និងស្រុកឥណ្ឌាមានប្រាសាទឈ្មោះចិត្រគុប្តក៏មាន (រូបលេខ១៣)។

ជារួមមក យោងតាមតឹកតាងមួយចំនួនដូចបានពន្យល់ខាងលើ យើងអាចសន្និដ្ឋានដំបូងថាចម្លាក់នៅលើផ្តែរទ្វារប្រាសាទភ្នំព្រះបាទ ដែលស្ថិតនៅក្នុងរចនាបថសំបូរព្រៃគុក ស.វ.ទី៧ អាចជាចម្លាក់ព្រះយមជិះលើសត្វក្របី និងអមសងខាងដោយសេនាកត់ត្រាពីរនាក់ដែលមានឈ្មោះថាចិត្រគុប្ត និងអគ្រ-សន្ធនី។ ចម្លាក់ព្រះយមនៅសម័យដំបូងរបស់ខ្មែរមានលក្ខណៈកម្រខ្លាំងណាស់ ហើយចម្លាក់ព្រះចិត្រគុបត្តក៏រឹតតែកម្រមានថែមទៀត។ ចម្លាក់នេះស្តែងឱ្យឃើញពីភាពចេះដឹងជ្រៅជ្រះរបស់ខ្មែរក្នុងការប្រណិប័តន៍ព្រហ្មញ្ញសាសនាកាលពីសម័យបុរាណ៕

[៨] Roveda 2005.

## ឯកសារយោង


**កំ វណ្ណារ៉ា**

២០២០, ប្រជុំសិលាចារឹកខេត្តកំពង់ស្ពឺ, ភ្នំពេញ។

**Boisselier, J.**

1966, "*Asie du Sud-Est, Le Cambodge* ", Tome I, Paris.

**Macdonall, A.A.**

1995, *Vedic mythology,* Motilal Banarsidass.

**Roveda, V.**

2005, *'Image of the gods',* Bangkok.

**Wilson, H.H.**

1895, *The Vishnu Purana,* Volume I, New Dehli.




រូបលេខ១៖ ផ្ទាំងចម្លាក់ទេពនព្វគ្រោះ រកឃើញនៅទួលវត្តចាស់ (តំបន់ប្រាសាទសំបូរព្រៃគុក)



រូបលេខ២៖ ចម្លាក់បង្ហាញព្រះយមជិះលើក្របីនៅលើផ្តែរប្រាសាទមេបុណ្យខាងកើត

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៣៖ ចម្លាក់បង្ហាញព្រះយមជិះនៅលើក្របីនៅលើហោជាងនិងផ្តែរទ្វារប្រាសាទបន្ទាយស្រី



រូបលេខ៤៖ ចម្លាក់ព្រះយមជិះលើក្របី (កញ្ចាំងនៅប្រាសាទអង្គរវត្ត)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៥៖ ចម្លាក់ព្រះយមជិះលើក្របី នៅជញ្ជាំងប្រាសាទអង្គរវត្ត



រូបលេខ៦៖ ចម្លាក់បដិមាព្រះយមធ្វើពីលោហៈ

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៧៖ ផ្តែរទ្វារប្រាសាទភ្នំព្រះបាទ ខេត្តកំពង់ចាម



រូបលេខ៨៖ ចម្លាក់បង្ហាញព្រះយម និងសេនាកត់ត្រា (ចិត្រគុប្ត) នៅប្រាសាទភ្នំព្រះបាទ



រូបលេខ៩៖ ចម្លាក់ព្រះយម នៅប្រាសាទភ្នំព្រះបាទ

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ១០៖ ចម្លាក់សេនាកត់ត្រារបស់ព្រះយម (ចិត្រគុប្ត) នៅប្រាសាទភ្នំព្រះបាទ

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ១១៖ ចម្លាក់បង្ហាញព្រះយម និងសេនាកត់ត្រានៅលើផ្តែរប្រាសាទវត្តភូ





រូបលេខ១២-១៣៖ ព្រះចិត្រគុបត្តនៅសិល្បៈសៀម និងឥណ្ឌា

(ប្រភព៖ https://en.wikipedia.org/wiki/Chitragupta ; https://vedicgoddess.weebly.com/bhakti-masala-blog/lord-chitragupta-lord-yamas-chief-accountant

អត្ថបទដោយ៖ ម៉ង់ វ៉ាលី